
K

# ល្បែងប្រកួតពណ៌

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ R4C

Rotary

កម្មវិធីសិក្សា៖

ចិត្តចលភាព ៖ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងសាច់ដុំភ្នែក) (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

បុរេគណិត ៖ (ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌)។

រយៈពេល ៖ ៣០ នាទី

សម្ភារ ៖ ក្រដាសល្បែងក្តារពណ៌ គ្រាប់ឡុកឡាក់

ឧបករណ៍ ៖ វត្ថុសម្រាប់រាប់ចំនួន ក្រដាសល្បែងក្តារពណ៌ គ្រាប់ឡុកឡាក់ គម្របដប ឬ ដុំថ្មតូចៗ។

គោលបំណង ៖

(ចិត្តចលភាព) ៖ ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

(បុរេគណិត) ៖ បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

សេចក្តីណែនាំ ៖

១. បែងចែកក្មេងៗទាំងអស់ទៅជាក្រុមៗ ដែលក្នុងក្រុមនីមួយៗ អាចមានសមាជិក ៦នាក់។

២. ចែកសន្លឹកល្បែងក្តារប្រកួតពណ៌ដែលមានទំហំ A3 មួយសន្លឹកគ្រាប់ឡុកឡាក់ ១គ្រាប់ និងវត្ថុសម្រាប់សម្គាល់។

៣. បោះគ្រាប់ឡុកឡាក់ និងផ្លាស់ប្តូរវេននរណាមានលេខខ្ពស់ជាងគេ អ្នកនោះនឹងត្រូវចាប់ផ្តើមមុនគេ។

៤. អ្នកវេនទី១ ចាប់ផ្តើមបោះគ្រាប់ឡុកឡាក់ និងរំកិលវត្ថុទៅតាមចំនួនលេខតាង ហើយពណ៌ចាំទីរបស់ខ្លួនចាំបាច់ត្រូវនឹងពណ៌គ្រាប់ឡុកឡាក់។

៥. ប្រសិនបើពណ៌គ្រាប់ឡុកឡាក់ខុសពីពណ៌របស់អ្នកចាំទីនោះគ្មានសិទ្ធរំកិលនោះទេ ហើយសមាជិកក្រុមដែលមានពណ៌ដូចមានសិទ្ធរំកិល។

៦. ផ្លាស់ប្តូរវេនឱ្យទៅក្មេងបន្ទាប់ដែលនៅជិតនោះធ្វើដូចរហូតគ្រប់គ្នា។

៧. ក្មេងៗណាម្នាក់ដែលឈានដល់គោលដៅមុនគេក្នុងចំណោមសមាជិកអ្នកនោះគឺជាអ្នកឈ្នះទី ១ ឈ្នះទី ២ ឈ្នះទី ៣.........។

បំបែបំរួល

-ប៉ុន្តែល្បែងប្រកួតពណ៌នេះយើងអាចលេងរបៀបផ្សេងក៏បានដែរ មានដូចខាងក្រោម៖

១. អ្នកចាំទីបោះគ្រាប់ឡុកឡាក់បានពណ៌មិនដូចខ្លួនមានត្រូវឱ្យអ្នកបន្ទាប់បោះម្តង ដោយមិនខ្វល់ថាអ្នកណាមានពណ៌ដូចគ្រាប់ឡុកឡាក់ហើយរំកិលតាមពណ៌នោះទេ។

២. មិនចាំបាច់បោះគ្រាប់ឡុកឡាក់រកអ្នកលេងមុនក៏បានដែរ។









